សាលាព្រះគម្ពីរភ្នំពេញ

លេខ២ ខែកក្កដា ២០១៤

# ព្រឹត្តិបត្រ វាលស្រែស្រូវទុំ

ប្រសាសន៍របស់លោកមហាវិទ្យាធិការ

www.ppbs.edu.kh

## ព្រះគ្រីស្ទមិនដែលឈប់ត្រាស់ហៅឡើយ ពេលទ្រង់ត្រាស់ហៅហើយ

ព្រះគ្រីស្ទត្រាស់ហៅកូនរបស់ទ្រង់ឲ្យបម្រើទ្រង់។ ពេលទ្រង់ត្រាស់ហៅហើយ ទ្រង់មិនឈប់ឡើយ។ គេបម្រើព័ន្ធកិច្ចក្នុងពេលវេលា និងទីកន្លែងផ្សេងគ្នា តាមអំណោយទាន និងការយល់ដឹងរបស់ខ្លួន។ ប៉ុន្តែមានអ្នកខ្លះបរាជ័យនិងបោះបង់ចោល ហើយអ្នកខ្លះទៀតយល់ខុសដោយអះអាងថា ទ្រង់ឈប់ត្រាស់ហៅគេ បន្ទាប់ពីការបម្រើព្រះមួយរយៈ ក៏បានបោះបង់ចោលការបម្រើព្រះនោះ។

ពេលព្រះគ្រីស្ទត្រាស់ហៅពួកសិស្សឲ្យទៅនេសាទមនុស្ស (ម៉ាកុស១:១៦-២០) ទ្រង់ជ្រាបជាមុនពីអ្វីដែលពួកគេនឹងធ្វើ។ ទ្រង់បញ្ជូនពីរនាក់ៗចេញទៅ(ប្រកាសដំណឹងល្អ)។ ពួកសិស្សរំភើបជាខ្លាំងក្នុងការធ្វើកិច្ចការនោះ។ គេមិនបានយកអ្វីទៅជាមួយឡើយ “លើកលែងតែដំបង១ប៉ុណ្ណោះ ឥតយកយាមនំប៉័ង ឬប្រាក់ដាក់ក្នុងខ្សែក្រវាត់ទេ”(ម៉ាកុស៦:៨)។ គេមានសេចក្តីត្រេកអរនៅក្នុងព័ន្ធកិច្ច(ម៉ាកុស៦:១២-១៣)។ គេបានប្តេជ្ញាចិត្ត ទុកចោលអ្វីៗទាំងអស់ ដើម្បីដើរតាមទ្រង់ (ម៉ាកុស ១០:២៨)។ ពួកគេបានការពារទ្រង់ និងការត្រាស់ហៅរបស់ព្រះអង្គ។ ពេលមនុស្សជាច្រើនបានបដិសេធមិនទទួលទ្រង់ នោះពួកសិស្ស១ចំនួនតូចបានសុំឲ្យមានភ្លើង មកបញ្ឆេះពួកមនុស្សទាំងនោះ(លូកា៩:៥៤)។ លោកពេត្រុសបានកាត់ត្រចៀកម្ខាងរបស់បាវបម្រើសម្តេចសង្ឃម្នាក់ ដែលបានមកចាប់ព្រះយេស៊ូវ(លូកា២២:៥០)។ គាត់បានប្រកាសផងដែរថា មិនបដិសេធព្រះគ្រីស្ទឡើយ ទោះបីជាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ(ម៉ាកុស១៤:២៩) តែគួរឲ្យសោកស្តាយ គាត់បានបដិសេធទ្រង់(យ៉ូហាន១៨:២៧)។ សិស្សផ្សេងទៀតបានបដិសេធទ្រង់នៅត្រង់ឈើឆ្កាង ហើយម្នាក់ក្នុងចំណោមសិស្សទាំង១២បានក្បត់ និងលក់ទ្រង់ ដើម្បីប្រាក់(យ៉ូហាន១៨:២)។ ពួកគេបានបរាជ័យចំពោះការត្រាស់ហៅរបស់ទ្រង់ ហើយបានវិលទៅប្រកបមុខរបរចាស់វិញ(យ៉ូហាន ២១)។ គេបានទាំងគិតថា ពេលវេលាដែលខ្លួនបានចំណាយជាមួយព្រះយេស៊ូវ ជាឥតប្រយោជន៍ទទេ។ តែការយល់បែបនេះគឺខុសហើយ ព្រះគ្រីស្ទមិនដែលឈប់ត្រាស់ហៅមនុស្សឲ្យធ្វើព័ន្ធកិច្ចឡើយ។ ក្រោយទ្រង់មានព្រះជន្មរស់ឡើងវិញ ទ្រង់បានទៅរកពួកគេ ហើយអះអាងបញ្ជាក់ថាគេនឹងទទួលព្រះវិញ្ញាណបរិសុទ្ធ(កិច្ចការ១:៨) ហើយគេនឹងបន្តធ្វើទីបន្ទាល់ប្រកាសពីការមានព្រះជន្មរស់ឡើងវិញ និងពីសេចក្តីសង្គ្រោះទៅកាន់មនុស្សទាំងអស់។ ពួកសិស្សទទួលការលើកទឹកចិត្ត និងស្អាងឡើង។ ក្រោយមកគេពិតជាបានដឹងថា ព្រះយេស៊ូវបានត្រាស់ហៅ និងបញ្ជូនគេឲ្យចេញទៅ ហើយពួកគេបានប្តេជ្ញាចិត្តតាមការត្រាស់ហៅ និងតាមព័ន្ធកិច្ចរបស់ទ្រង់។ ជាលទ្ធផល ពួកគេបានប្រកាស និងការពារដំណឹងល្អ រហូតដល់ហ៊ានលះបង់ជីវិតរបស់ខ្លួនទៀតផង។

មាននិស្សិតម្នាក់បានចែករំលែកព្រះបន្ទូល លើកទឹកចិត្តមិត្តភក្តិខ្លួនឲ្យបន្តការប្តេជ្ញាចិត្ត បម្រើព្រះជាម្ចាស់ក្នុងពួកជំនុំដើមរបស់ខ្លួន។ គាត់បាននិយាយថា យើង(និស្សិត) បានប្តេជ្ញាចិត្តថា នឹងវិលត្រឡប់ទៅពួកជំនុំដើមរបស់យើងវិញ ដើម្បីបម្រើព្រះជាម្ចាស់ ទោះបីជាត្រូវប្រឈមនឹងការលំបាកច្រើនយ៉ាងណាក៏ដោយ។ តែមាននិស្សិតខ្លះបានបរាជ័យ ហើយនិស្សិតផ្សេងទៀតអាចនឹងបរាជ័យ បន្ទាប់ពីបានដើរជាមួយនឹងព្រះ នៅក្នុងដំណើរជីវិតដ៏វែងឆ្ងាយនៃការបម្រើទ្រង់។ យើងមិនគួរបារម្ភអំពីជីវិតនិងសុវត្ថិភាពផ្ទាល់ខ្លួនរបស់យើងពេកទេ ព្រោះការនេះនាំឲ្យយើងជ្រើសរើសយកជីវិតស្រណុកស្រួល ជាជាងតាមការដឹកនាំរបស់ព្រះ ដែលអាចតម្រូវឲ្យយើងតស៊ូក្នុងការលំបាកខ្លះៗ។ និស្សិតនោះបានសួរថា “តើការប្តេជ្ញាចិត្តដំបូងរបស់យើងចំពោះការត្រាស់ហៅរបស់ព្រះ នោះនៅឯណាឥឡូវនេះ?” សំណួរនេះបានប៉ះពាល់ចិត្តយើង(ទាំងអ្នកទាំងខ្ញុំ)។ ចូរយើងក្រលេកមើលទៅក្រោយ ហើយពិនិត្យមើលខ្លួនយើងបន្តិច ថាតើយើងបរាជ័យក្នុងការប្តេជ្ញាចិត្ត ចំពោះការត្រាស់ហៅរបស់ព្រះ ដើម្បីរស់នៅ និងប្រកាសដំណឹងល្អដូចពួកសិស្សទាំង១២ឬទេ? ប្រហែលជាយើងបរាជ័យ តែព្រះគ្រីស្ទតែងតែមករកយើងដោយសេចក្តីស្រឡាញ់ សន្តោស និងការលើកទឹកចិត្ត ដោយមានបន្ទូលមកកាន់យើង និងស្អាងចិត្តយើង។ទ្រង់បានត្រាស់ហៅយើង ហើយមិនដែលឈប់ត្រាស់ហៅឡើយ។ ទ្រង់ចង់បានយើងរស់នៅ ប្រកាស និងការពារដំណឹងល្អ ក្នុងពិភពលោកដែលបាក់បែកមួយនេះ។ ទ្រង់ចង់បានយើងប្រកាសដំណឹងល្អរហូតដល់យើងលាចាកពីផែនដីនេះទៅ។ តើយើងកំពុងតែឆ្លើយតបចំពោះការត្រាស់ហៅរបស់ទ្រង់ដោយភាពវិជ្ជមានឬទេ?



ទេព សំណាង

មហាវិទ្យាធិការនៃសាលាព្រះគម្ពីរភ្នំពេញ

# បទពិសោធន៍របស់សាស្ត្រាចារ្យ Shirley Zhang បង្រៀននៅសាលាព្រះគម្ពីរភ្នំពេញរយៈពេល៣ឆ្នាំ : មេរៀនសំខាន់បំផុតដែលខ្ញុំបានរៀន

អស់រយៈពេល៣ឆ្នាំ ដែលខ្ញុំបានភ្លក់ និង បានមើលឃើញ ពីសេចក្តីល្អរបស់ព្រះ នៅក្នុងសាលាព្រះគម្ពីរភ្នំពេញ ក្នុងពេលល្អ និងពេលលំបាក។ ប៉ុន្តែ នៅក្នុងដំណើរជីវិតនោះ មានការអស្ចារ្យយ៉ាងខ្លាំង។ វាបានផ្តល់ឱកាសដល់ខ្ញុំ ស្វែងរកឃើញថាតើខ្ញុំមានពរយ៉ាងណា ដំណើរនេះបានជួយខ្ញុំរកឃើញគោលបំណងនៃជីវិតនិងបេសកកម្មរបស់ខ្ញុំនៅលើផែនដីនេះ នាំដំណឹងល្អទៅដល់ចុងបំផុតនៃផែនដី បានជួយខ្ញុំយល់ពីអត្ថន័យនៃការលីឈើឆ្កាងរបស់ខ្ញុំ រាល់ថ្ងៃតាមទ្រង់។ ពេលខ្ញុំមើលទៅក្រោយវិញ រយៈពេល៣ឆ្នាំមកនេះ ខ្ញុំមិនដែលខ្វះអ្វីទាល់តែសោះ កន្លែងស្នាក់នៅ អាហារ សំលៀកបំពាក់ សុខភាព មិត្តភក្តិ អ្នកផ្គត់ផ្គង់ដៃគូរអធិស្ឋាន អំណរបានពីការស្គាល់និងបម្រើរាស្ត្រទ្រង់ រួមចំណែកជាមួយនឹងភាពបាក់បែកនៃជីវិតអ្នកឯទៀតៗ និងការដើរជាមួយពួកគេ នៅក្នុងពេលពួកគេជួបស្ថានភាពលំបាកនានា។ រាល់អ្វីៗដែលខ្ញុំត្រូវការ ទ្រង់ផ្គត់ផ្គង់ដោយស្មោះពីពេលមួយទៅពេលមួយ ធ្វើឲ្យខ្ញុំចាប់ផ្តើមមានអារម្មណ៍យ៉ាងល្អ អំពីខ្លួនឯង លះបង់សេចក្តីស្រណុកស្រួលរបស់ខ្ញុំ សម្រាប់ព័ន្ធកិច្ចរបស់ទ្រង់។ ខ្ញុំបានគិតថា: ខ្ញុំកំពុងតែជួយព្រះ។ ព្រះត្រូវការខ្ញុំជួយនៅទីនេះ។ តែការពិតគឺខ្ញុំទេដែលត្រូវការការលូតលាស់និងរីកចម្រើន។ ខ្ញុំទេដែលត្រូវសម្អាតឲ្យបរិសុទ្ធនិងពន្លាតសេចក្តីជំនឿ។ ព្រះបានរំឭកខ្ញុំថាទ្រង់អាចប្រើខ្ញុំនៅទីនេះ មិនមែនដោយសារខ្ញុំឆ្លាតជាងគេទេ តែដោយព្រោះតែព្រះគុណ និងសេចក្តីស្រឡាញ់ដល់ខ្ញុំប៉ុណ្ណោះ។ ទ្រង់កំពុងបង្ហាត់ខ្ញុំ ឲ្យយកឈ្នះដែនកំណត់ និងអ្វីៗដែលទាញខ្ញុំឲ្យថយក្រោយ។ នោះគឺជាមេរៀន១សំខាន់បំផុតដែលខ្ញុំបានរៀន។ ខ្ញុំអរព្រះគុណដល់ព្រះដែលបានត្រាស់ និងតែងតែគង់នៅជាមួយ នៅក្នុងដំណើរជីវិតរបស់ខ្ញុំ។ ពេលព្រះត្រាស់ហៅខ្ញុំទៅធ្វើព័ន្ធកិច្ចមួយទៀតនៅក្រុងភ្នំពេញ ខ្ញុំពិបាកចិត្តនឹងចាកចេញពីសាលាព្រះគម្ពីរភ្នំពេញ ដែលជាផ្ទះដ៏កក់ក្តៅរបស់ខ្ញុំក្នុងរយៈពេល៣ឆ្នាំមកនេះ។ ខ្ញុំនឹងនឹករឭកដល់ការធ្វើការជាមួយនឹងមិត្តរួមការងារទាំងអស់ នៅសាលាព្រះគម្ពីរភ្នំពេញ។ "ឯព្រះដែលបានហៅអ្នករាល់គ្នាមក ឲ្យមានសេចក្តីប្រកបនឹងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង នោះទ្រង់ស្មោះត្រង់" ១កូរ.១:៩



## ទំព័រជួបជាមួយនឹងជំនួយការថ្មីផ្នែកបណ្ណាល័យ



ស្រីមុំចាប់ផ្តើមធ្វើការជាជំនួយការផ្នែកបណ្ណាល័យតាំងពីខែកញ្ញា ឆ្នាំ២០១៣ មកដល់ពេលនេះជិត១ឆ្នាំហើយ។

### តើអ្នកចូលចិត្តធ្វើការនៅក្នុងបណ្ណាល័យយ៉ាងដូចម្តេចដែរ?

ខ្ញុំរីករាយជាខ្លាំង ក្នុងការធ្វើការជាមួយសាស្ត្រាចារ្យ ព្រមទាំងនិស្សិតទាំងអស់ជារៀងរាល់ថ្ងៃ។ ការបំពេញការងារនៅទីនេះបានជម្រុញទឹកចិត្តរបស់ខ្ញុំ យល់ដឹងច្រើនឡើងអំពីព្រះបន្ទូល ក៏បានធ្វើឲ្យខ្ញុំចង់ធ្វើជានិស្សិតនៃសាលាព្រះគម្ពីរភ្នំពេញផងដែរ។ ខ្ញុំចូលចិត្តចំពោះការប្រកបស្និទ្ធស្នាលជាមួយសាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់។ យើងបានជួបជុំ

### តើអ្នកប្រឈមមុខនឹងបញ្ហាអ្វីខ្លះក្នុងការងាររបស់អ្នក?

ខ្ញុំមិនមែនជាបណ្ណារក្សជំនាញទេ តែព្រះជាម្ចាស់បានប្រទានព្រះគុណដល់ខ្ញុំ ធ្វើជាជំនួយការបណ្ណារក្ស។ នេះជាតួនាទីថ្មីបំផុតសម្រាប់ខ្ញុំ។ តែដោយមានការជួយពីព្រះជាម្ចាស់ និងពីប្រធានបណ្ណារក្ស នោះខ្ញុំអាចចាត់ចែងការងាររបស់ខ្ញុំបានល្អ ខ្ញុំកំពុងតែអភិវឌ្ឍជំនាញរបស់ខ្ញុំ ដើម្បីបម្រើដល់និស្សិត និងសាស្ត្រាចារ្យឲ្យបានកាន់តែប្រសើរឡើង។

### តើអ្នកបានរៀនអ្វីខ្លះក្នុងរយៈពេល១ឆ្នាំមកនេះនៅសាលាព្រះគម្ពីរភ្នំពេញ?

ខ្ញុំរៀនបានច្រើនណាស់។ ធ្វើការជាមួយនិស្សិតពិតជាត្រូវការសេចក្តីអត់ធ្មត់ខ្លាំង។ និស្សិតខ្លះនៅកំពុងលូតលាស់ខាងព្រលឹងវិញ្ញាណឆ្ពោះទៅរកភាពចាស់ទុំនៅឡើយ ខ្ញុំបានរៀនអត់ធ្មត់ នៅពេលពួកគាត់មិន





ធ្វើតាមច្បាប់បណ្ណាល័យ ប៉ុន្តែខ្ញុំនៅតែស្រឡាញ់រាប់អានពួកគាត់ ដោយព្រោះពួកគាត់ជាបងប្អូនប្រុសស្រីរួមជំនឿរបស់ខ្ញុំ។

# អបអរសាទរដល់និស្សិតដែលទទួលសញ្ញាបត្រទាំងអស់!

ឆ្នាំនេះមាននិស្សិតដប់ពីររូបនឹងទទួលសញ្ញាបត្រ គឺប្រាំបួនរូបនឹងទទួលសញ្ញាបត្របរិញ្ញាបត្រព័ន្ធកិច្ចគ្រីស្ទាន(BCM) ហើយបីរូបនឹងទទួលសញ្ញាបត្ររងព័ន្ធកិច្ចគ្រីស្ទាន(ADCM)។ យើងអរព្រះគុណព្រះជាម្ចាស់សម្រាប់និស្សិត១ក្រុមថែមទៀតដែលបានឆ្លើយចំពោះការត្រាស់ហៅរបស់ព្រះ ធ្វើព័ន្ធកិច្ចរបស់ទ្រង់។ នេះជាសេចក្តីអំណររបស់យើង មើលឃើញយុវជនទាំងនេះថ្វាយខ្លួនដល់នគររបស់ទ្រង់។ សូមអបអរសាទរ ! ធ្វើបានប្រពៃហើយ!

## មុខវិជ្ជាដែលខ្ញុំចូលចិត្តខ្លាំងជាងគេ :

ខ្ញុំចូលចិត្តមុខវិជ្ជាទាំងអស់។ មុខវិជ្ជាដែលខ្ញុំចូលចិត្តខ្លាំងជាងគេគឺមុខវិជ្ជាភាពជាអ្នកដឹកនាំតាមព្រះគម្ពីរ។ មុខវិជ្ជានេះបានបង្រៀនខ្ញុំថាអ្នកដឹកនាំត្រូវមានអត្តចរិតបែបណា ដើម្បីឲ្យអាចដឹកនាំរាស្ត្ររបស់ព្រះជាម្ចាស់បានល្អប្រសើរ។ ខ្ញុំត្រូវអនុវត្តគោលការណ៍ទាំងអស់នោះក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំក៏បានរៀនពីរបៀបលើកទឹកចិត្ត របៀបបង្រៀន និងរបៀបដោះស្រាយបញ្ហានានា។ ខ្ញុំអរព្រះគុណដល់ព្រះ ដែលខ្ញុំអាចប្រើប្រាស់នូវអ្វីៗ ដែលខ្ញុំបានរៀននៅសាលាព្រះគម្ពីរភ្នំពេញ ដើម្បីធ្វើព័ន្ធកិច្ចរបស់ខ្ញុំ បន្ទាប់ពីខ្ញុំរៀនចប់។



អេង សំអុន
(បរិញ្ញាបត្រ)

មុខវិជ្ជាការដាំនិងការលូតលាស់របស់ពួកជំនុំ មានប្រយោជន៍ណាស់ចំពោះខ្ញុំ ព្រោះព័ន្ធកិច្ចរបស់ខ្ញុំនៅថ្ងៃអនាគត តម្រូវឲ្យខ្ញុំដាំពួកជំនុំ។ ការដាំពួកជំនុំប្រៀបដូចជាសង់អាគារ១អញ្ចឹង។ ដើម្បីឲ្យពួកជំនុំរឹងមាំ យើងត្រូវតែមានគ្រឹះឲ្យបានមាំ។ មុខវិជ្ជានេះបានបង្រៀនខ្ញុំអំពីវិធីសាស្ត្រជាច្រើន ដើម្បីសង់ពួកជំនុំយ៉ាងរឹងមាំមួយ។ មុខវិជ្ជានេះបានផ្តល់ឲ្យខ្ញុំនូវការរៀបចំខ្លួនយ៉ាងល្អមួយសម្រាប់អនាគតរបស់ខ្ញុំ។



វៃ ចាន់ណែត
(បរិញ្ញាបត្រ)

## តើអ្នកចង់អរព្រះគុណដល់ព្រះជាម្ចាស់សម្រាប់អ្វី?

ខ្ញុំអរព្រះគុណ ដែលទ្រង់បានថែរក្សាការពារខ្ញុំ ពេលដែលខ្ញុំកំពុងរៀននៅសាលាព្រះគម្ពីរភ្នំពេញ ពេលខ្ញុំចាប់ផ្តើមរៀន ពេលនោះមានអ្នកឧបត្ថមដល់ខ្ញុំ។ ប៉ុន្តែបន្ទាប់ពីឆ្នាំទីពីរទៅ ខ្ញុំបាត់បង់ការឧបត្ថមទាំងអស់។ ពេលនោះខ្ញុំខូចចិត្តយ៉ាងខ្លាំងហើយចង់ឈប់រៀន។ តែក្រោយមក ព្រះបានប្រទានការឧបត្ថមជាថ្មី ដើម្បីឲ្យខ្ញុំអាចបញ្ចប់ការសិក្សាបានល្អប្រសើរ។ ខ្ញុំសរសើរទ្រង់ ដែលទោះបីជាខ្ញុំជួបការលំបាកខ្លាំង នៅពេលខ្លះក៏ដោយ ទ្រង់តែងតែគង់ជាមួយខ្ញុំនិងកំសាន្តចិត្តខ្ញុំ។ ទ្រង់មិនដែលទុកខ្ញុំចោលទេ។



ទឹម រស្មី
(បរិញ្ញាបត្រ)

## តើអ្នកមានដំបូន្មានអ្វីខ្លះផ្តល់ជូននិស្សិតដែលកំពុងរៀននៅឡើយ?

ចូរតស៊ូក្នុងសេចក្តីត្រាស់ហៅ ដែលព្រះជាម្ចាស់បានប្រទានតាំងពីដើមដំបូង។ ចូរផ្តោតចិត្តឲ្យបានខ្លាំងនិងព្យាយាមអស់ពីលទ្ធភាព បើទោះបីជាអ្នករៀនខ្សោយក៏ដោយ។ បន្តការជឿទុកចិត្តព្រះជាម្ចាស់ និងបន្តស្មោះត្រង់ចំពោះទ្រង់។ អនុវត្តការចាត់ចែងពេលវេលារបស់អ្នកឲ្យបានល្អប្រសើរ ដោយដឹងថានិស្សិតទាំងអស់សុទ្ធតែជួបការលំបាក មិនមែនតែអ្នកម្នាក់ឯងទេ ហេតុនេះចូរស្វែងរកជំនួយពីនិស្សិតដទៃទៀតផងដែរ។



ម៉ុន បញ្ញា
(បរិញ្ញាបត្រ)

# “ពីព្រោះព្រះដ៏មានព្រះចេស្តា ទ្រង់បានប្រោសសេចក្តីយ៉ាងល្អវិសេសដល់ខ្ញុំ ព្រះនាមទ្រង់បរិសុទ្ធ”

(លូកា ១:៤៩)

## តើអ្នកនឹងធ្វើព័ន្ធកិច្ចអ្វីពេលបញ្ចប់ពីទីនេះ?

ខ្ញុំកំពុងធ្វើព័ន្ធកិច្ចនៅក្នុងរោងចក្រសំលៀកបំពាក់មួយកន្លែង នៅក្រុងតាខ្មៅ ដែលមានចំនួនកម្មករជាងមួយពាន់នាក់។ រៀងរាល់ព្រឹក ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ខ្ញុំបង្រៀនព្រះបន្ទូលព្រះ ដល់កម្មករទាំងអស់ក្នុងរោងចក្រនេះ មុនពេលពួកគេចាប់ផ្តើមធ្វើការ។ យើងបានបង្កើតក្រុមសិក្សាគម្ពីរមួយមានកម្មករ១៥នាក់។ និមិត្តរបស់ខ្ញុំគឺចង់បង្កើតព្រះវិហារមួយនៅក្បែររោងចក្រនោះ ដើម្បីឲ្យកម្មកររោងចក្រអាចថ្វាយបង្គំព្រះ។ សូមអធិស្ឋានសម្រាប់ខ្ញុំផង។ ខ្ញុំត្រូវការជំនួយដើម្បីសង់ព្រះវិហារមួយ និងសូមអធិស្ឋានសូមព្រះជាម្ចាស់ផ្គត់ផ្គង់សេចក្តីត្រូវការនៃគ្រួសាររបស់ខ្ញុំ និងព័ន្ធកិច្ចរបស់ខ្ញុំផងដែរ។



ជុត សុភួង
(បរិញ្ញាបត្រ)

## អ្វីដែលខ្ញុំនឹងនឹករឭកអំពីសាលាព្រះគម្ពីរភ្នំពេញ :

ខ្ញុំនឹងនឹករឭកទេសភាពដ៏ស្រស់ត្រកាល នៃបរិវេណសាលាព្រះគម្ពីរភ្នំពេញ។ ព្រះជាម្ចាស់បានប្រទានទីកន្លែងយ៉ាងល្អ១សម្រាប់ពួកយើងសិក្សានិងស្នាក់នៅ ហើយប្រទានអាហារយ៉ាងបរិបូរសម្រាប់យើងបរិភោគផងដែរ។ ខ្ញុំក៏នឹងនឹករឭកដល់មិត្តភក្តិរបស់ខ្ញុំទាំងអស់។ ពេលខ្ញុំសិក្សានៅឆ្នាំទី១ មានពេល១ ដែលខ្ញុំមានជម្ងឺធ្ងន់មែនទែន មិត្តភក្តិជាច្រើនបានយកចិត្តទុកដាក់ចំពោះខ្ញុំ។ ខ្ញុំក៏នឹងនឹករឭកដល់សាស្ត្រាចារ្យនិងការប្រកបគ្នានៅក្រុមតូចប្រចាំសប្តាហ៍ផងដែរ ដែលជាកន្លែងដែលធ្វើឲ្យយើងមានអារម្មណ៍សុវត្ថិភាព ដើម្បីចែករំលែកពីបញ្ហាលំបាកទាំងឡាយ ហើយគ្រូក្រុមតូចរបស់យើងបានណែនាំ និងលើកទឹកចិត្តយើងធ្វើព័ន្ធកិច្ច។ ខ្ញុំពិតជានឹងនឹករឭកដល់សាលាព្រះគម្ពីរភ្នំពេញយ៉ាងខ្លាំង ។



ប៉ុន រតនៈ
(បរិញ្ញាបត្រ)



ខែម សុខុម
(បរិញ្ញាបត្រ)



ចាន់ សុភាព
(បរិញ្ញាបត្រ)



ហាុង សម្ពស្ស
(បរិញ្ញាបត្រ)



ប៊ុត ពិសិដ្ឋ
(បរិញ្ញាបត្ររង)



ហ៊ុន ច័ន្ទសាមី
(បរិញ្ញាបត្ររង)



ឈិត ផារី
(បរិញ្ញាបត្ររង)

## យើងខ្ញុំសូមថ្លែងអំណរគុណចំពោះដង្វាយរបស់លោកអ្នក!

នាម:____________________ អស័យដ្ឋាន ឬ អ៊ីមែល:____________________

លេខទូរស័ព្ទ:____________________ មកពីពួកជំនុំឬអង្គការ:____________________

**របៀបដែលលោកអ្នកអាចថ្វាយដង្វាយ:**

$____________________ ឬ ថ្វាយដង្វាយរបស់លោកអ្នកដោយបញ្ចូលទៅក្នុងធនាគារកម្ពុជាសាធារណៈ: គណនីលេខ # ០៩០ ០២ ១១ ០០ ១៥២១ ឬប្រគល់ជូនផ្ទាល់ដល់ផ្នែកហិរញ្ញវត្ថុរបស់សាលាព្រះគម្ពីរភ្នំពេញ។

**សូមបញ្ជាក់ឲ្យបានច្បាស់ដង្វាយរបស់លោកអ្នកសម្រាប់:**

- ការប្រើប្រាស់ទូទៅ ☐
- ឧបត្ថម្ភដល់និស្សិត ☐
- អភិវឌ្ឍអាគារសិក្សា ☐
- ឧបត្ថម្ភដល់បណ្ណាល័យ ☐

#២៥៥ ផ្លូវ២៨គ្រួសារ ភូមិរោងចក្រ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ប្រអប់សំបុត្រ ១១៥៤ ទូរស័ព្ទលេខ ០១២ ៩៣៩ ៥០៩

អ៊ីម៉ែល ppbs@ppbs.edu.kh វិបសាយ www.ppbs.edu.kh